ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាខេត្តឧត្តរមានជ័យ**
លេខ ៖ ១២៤ -សជណ/ឧជ

ឧត្តរមានជ័យ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៤

## សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤

**យោង ៖** ប្រកាសលេខ ៥៤៨ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យសូមជម្រាបជូនដំណឹងដល់ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងអស់ឲ្យបានជ្រាបថា ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ នឹងត្រូវចាប់អនុវត្តពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ។**

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទអាចបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត, ការិយាល័យពន្ធដារក្រុង-ស្រុក ឬនៅធនាគារអេស៊ីលីដា ភីអិលស៊ី ដោយត្រូវបំពេញលិខិតប្រកាសបង់ពន្ធចំនួន ០២សន្លឹកតាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក ទោចក្រយានយន្ត និងត្រីចក្រយានយន្តដែលបំពាក់ដោយម៉ាស៊ីនម៉ូតូ មិនមានកាតព្វកិច្ចបំពេញលិខិតប្រកាស និងមិនចាំបាច់ភ្ជាប់មកជាមួយនូវឯកសារផ្សេងៗទេ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះអាចស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណសម្គាល់ការបង់ពន្ធរបស់ខ្លួនដើម្បីប្រើប្រាស់ក្នុងការបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធខាងមុខទៀតបានដោយមិនចាំបាច់បំពេញលិខិតប្រកាសបង់ពន្ធសារជាថ្មី ក្នុងតម្លៃ ៥.០០០រៀល ។

*ក្នុងពេលប្រកាសបង់ពន្ធ ម្ចាស់មធ្យោបាយត្រូវភ្ជាប់មកជាមួយនូវ ៖*

-ប័ណ្ណសម្គាល់យានយន្ត ឬវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត (ឈៀក) ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬបង្កាន់ដៃបង់ពន្ធនាំចូល ឬលិខិតបញ្ជាក់ការប្រើប្រាស់ដែលចេញដោយមេឃុំ-ចៅសង្កាត់ ចំពោះយានយន្តពុំទាន់បានចុះបញ្ជី ។

-អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់សំបុត្រកំណើតចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ។

ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទនីមួយៗ មិនគិតថាជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនឡើយ (តារាងកំណត់តម្លៃមានបិទផ្សព្វផ្សាយជូននៅតាមទីតាំងបង់ពន្ធនីមួយៗ) លើកលែងតែរថយន្តដែលទទួលបានការអនុគ្រោះពិសេសពីរាជរដ្ឋាភិបាល ដែលម្ចាស់យានយន្តត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារដើម្បីទទួលបាននូវលតាបត្រលើកលែងពន្ធ ។ ដោយឡែក ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះណាដែលមិនបានបង់ពន្ធបណ្តាឆ្នាំកន្លងមក ត្រូវបានលើកលែងពន្ធ និងប្រាក់ពិន័យសម្រាប់ការខកខានកន្លងមក ប៉ុន្តែម្ចាស់យានយន្តទាំងនោះត្រូវមានកាតព្វកិច្ចបង់ពន្ធចាប់ពីឆ្នាំ២០១៤នេះតទៅ ។

អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យឲ្យបង់ពន្ធ និងផាកពិន័យចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះណាដែលមិនទាន់បានប្រកាសបង់ពន្ធ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ ខាងមុខនេះតទៅ ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា លោកលោកស្រីជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ នឹងអនុវត្តកាតព្វកិច្ចបង់ពន្ធនេះបានទាន់ពេលវេលា ដើម្បីជៀសផុតពីការពិន័យជាក់ជាមិនខាន ។

**អភិបាលខេត្ត**

ស-ថាវី

<u>ចម្លងជូន ៖</u>
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រុមប្រឹក្សាខេត្ត
"ដើម្បីជូនជ្រាប"
-សាខាពន្ធដារខេត្ត
-ធនាគារអេស៊ីលីដា ភីអិលស៊ី
សាខាខេត្តឧត្តរមានជ័យ
"ដើម្បីមុខការ"
-សាលាក្រុងសំរោង និងស្រុកទាំង ៤
"ដើម្បីផ្សព្វផ្សាយ និងសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ